# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សាលក្រមលេខ: ៩៣ "ឃ"
ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២
សំណុំរឿងរដ្ឋប្បវេណីលេខ: ២១៦
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃព្រហស្បតិ៍ ២កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។

លើសំណុំរឿងរដ្ឋប្បវេណីលេខ: ២១៦ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១។

ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

**ដើមចោទ**

-ឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ កើតឆ្នាំ១៩៨៧ មុខរបរ: នគរបាល មានអាសយដ្ឋានបច្ចុប្បន្ន [redacted]

**ចុងចម្លើយ**

-ឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ កើតឆ្នាំ១៩៨៣ មុខរបរ ប៉ូលិស មានអាសយដ្ឋានបច្ចុប្បន្ននៅ [redacted]

-លោក [redacted] អត្តលេខ: ១៥៧ និងលោក [redacted] អត្តលេខ: ២៣១០T ជាសមាជិកគណ:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានការិយាល័យ [redacted] និងជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់។

-លោកស្រី [redacted] ជាសមាជិកគណ:មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានការិយាល័យមេធាវី [redacted] មានអាសយដ្ឋានស្ថិតនៅផ្ទះ

[redacted] និងជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់។

**អង្គហេតុ និងចំណុចវិវាទ**

ខ្លឹមសារដែលដើមចោទទាមទារឱ្យតុលាការចេញសាលក្រមៈ

១-សុំផ្តាច់សមគ្គសង្វាស (លែងលះ) ពីចុងចម្លើយឈ្មោះ [redacted] ដារ៉ា ([redacted] សារ៉ាត់)។

២-សុំគ្រប់គ្រងកូនឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ និង ឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ មកចិញ្ចឹមបីបាច់ថែរក្សា។

៣-សុំទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនក្នុងមួយខែចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក។

៤-ទ្រព្យសម្បត្តិរួមមានៈ

ក.រថយន្តម៉ាក Prius ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ស្លាកលេខ ភ្នំពេញ **២BI-៧៩៥៧** នាងខ្ញុំសុំគ្រប់គ្រង។

ខ.ផ្ទះថ្មីទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ចុងចម្លើយ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ ប្រគល់ឱ្យទៅចុងចម្លើយ ជាអ្នកគ្រប់គ្រង។

គ.ដីឡូត៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងដីឡូត៍លេខ Q៨៩ បណ្តោយ ២០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ ទំហំ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃក្តី ឃុំព្រៃព្វច ស្រុកអង្គស្នួល ខេត្តកណ្តាល នាងខ្ញុំសុំគ្រប់គ្រង។

៥.បំណុលរួមមានៈ

ក.ជំពាក់ធនាគារ អេប៊ីអេ ប្រហែលចំនួន ៤៥,០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក យកមកធ្វើផ្ទះនៅលើដីចុងចម្លើយខាងលើ សុំឱ្យចុងចម្លើយជាអ្នកសងបំណុលទៅធនាគារតែម្នាក់ឯង។

ខ.តុងទីនចំនួន ១០ ក្បាល លេងនៅស្នងការខេត្តកំពង់ស្ពឺ នាងខ្ញុំបានបង់ជារៀងរាល់ខែ ចំនួន ២,៧០០,០០០ (ពីរលានចិតសិបម៉ឺន) រៀល នាងខ្ញុំជាអ្នកទទួលបង់តែម្នាក់ឯង។

៦.ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

**ការពន្យល់ត្រួសៗអំពីរឿងក្តី**

នាងខ្ញុំ និងចុងចម្លើយឈ្មោះ [redacted] ដារ៉ា ([redacted] សារ៉ាត់) បានរៀបការតាមប្រពៃណីនៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០០៩ និងបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩។ បន្ទាប់ពីនាងខ្ញុំ និងចុងចម្លើយរួមរស់នៅជាមួយគ្នាអស់រយៈពេល ១២ឆ្នាំ មានកូនពីរនាក់ ឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ និងឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៩។ ទ្រព្យសម្បត្តិរួមមាន: រថយន្តម៉ាក Prius ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ស្លាកលេខ: ភ្នំពេញ ២BI-៧៩៥៧, ផ្ទះថ្មទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ចុងចម្លើយ, ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០, ដីឡូត៍លេខ X២០៤ ទំហំ (៥x២០) ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងដីឡូត៍លេខ Q៨៩ បណ្តោយ ២០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ ទំហំ

១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រែកក្តី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ: ០៨២/១៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥, ទ្រព្យសម្បត្តិដោយឡែកមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ ជារបស់ចុងចម្លើយ និងបំណុលជំពាក់ធនាគារ [redacted] ប្រហែលចំនួន ៤៥,០០០ (បួនម៉ឺនប្រាំពាន់) ដុល្លារអាមេរិក យកមកធ្វើផ្ទះនៅលើដីចុងចម្លើយខាងលើ និងជំពាក់តុងទីនចំនួន ១០ ក្បាល លេងនៅស្នងការខេត្តកំពង់ស្ពឺ នាងខ្ញុំបានបង់ជារៀងរាល់ខែចំនួន ២,៧០០,០០០ (ពីរលានចិតសិបម៉ឺន) រៀល។ ក្រោយពីនាងខ្ញុំរស់នៅជាមួយចុងចម្លើយអស់រយៈពេល ១២ឆ្នាំ មកនេះ នាងខ្ញុំ និងចុងចម្លើយ តែងតែមិនចុះសម្រុងនឹងគ្នា ដោយមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ ដោយចុងចម្លើយមានស្រីនៅខាងក្រៅ ហើយនាងខ្ញុំបានហាមចុងចម្លើយជាច្រើនដង តែចុងចម្លើយនៅតែមិនព្រមកែខ្លួន ជាពិសេសចុងចម្លើយធ្លាប់ប្រើអំពើហិង្សាមកលើរូបនាងខ្ញុំថែមទៀត ហើយនាងខ្ញុំចេះតែទ្រាំរហូតមក មានពេលខ្លះចុងចម្លើយបានសុំនាងខ្ញុំលែងលះថែមទៀតផង តែនាងខ្ញុំមិនព្រមព្រោះនាងខ្ញុំមានការអាណិតដល់កូនខ្លាចកូនកំព្រា ដោយនៅពេលថ្មីៗនេះ ចុងចម្លើយតាមកេរៀងនាងខ្ញុំមិនឈប់សោះ ហើយថែមទាំងចោទនាងខ្ញុំថា នាងខ្ញុំមានប្រុសទាំងដែលនាងខ្ញុំខំរកលុយផង ធ្វើការផងដើម្បីរកលុយមកចិញ្ចឹមកូន បែរជាចុងចម្លើយមិនផ្តល់តម្លៃ មើលងាយដល់រូបនាងខ្ញុំថែមទៀត ដែលធ្វើឱ្យនាងខ្ញុំអស់នូវមនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធតទៅទៀតហើយ ទើបនាងខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការនេះតែម្តង។

**ការអះអាងរបស់ភាគី**

-ដើមចោទឈ្មោះ [redacted] អាយុវន្ត បានធ្វើសេចក្តីថ្លែងការណ៍ពីលទ្ធផលត្រៀមសម្រាប់ការទាញហេតុផលថា: នាងខ្ញុំនៅតែសុំឱ្យតុលាការឱ្យនាងខ្ញុំបានលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់ ដដែល ដោយមិនព្រមត្រូវគ្នាវិញទេ។ នាងខ្ញុំ និងចុងចម្លើយឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់ បានរៀបការតាមប្រពៃណីនៅឆ្នាំ២០០៩ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅឆ្នាំ២០០៩។ ក្រោយពីនាងខ្ញុំរួមរស់ជាមួយចុងចម្លើយអស់រយៈពេល ១២ឆ្នាំ មានកូនពីរនាក់ ទី១.ឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ និងទី២.ឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ទ្រព្យសម្បត្តិរួមមាន: រថយន្តម៉ាក Prius មួយគ្រឿង ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ផ្លាកលេខ ភ្នំពេញ ២BI-៧៩៥៧, ផ្ទះថ្មទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ចុងចម្លើយ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០, ដីឡូត៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងដីឡូត៍លេខ Q៨៩ ទំហំ (៥x២០) ម៉ែត្រ ស្មើ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រែកក្តី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ: ០៨២/១៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥, ទ្រព្យសម្បត្តិដោយឡែកមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ របស់ចុងចម្លើយ និងបំណុលរួមជំពាក់ធនាគារ អេប៊ីអេ ចំនួន ៤២,០៨៣.២៧ (បួនម៉ឺនពីរពាន់សូន្យរយប៉ែតសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក យកមកធ្វើផ្ទះនៅលើដីដោយឡែក

របស់ចុងចម្លើយខាងលើ និងជំពាក់គុងទីនចំនួន ១០ ក្បាល លេងនៅស្នងការខេត្តកំពង់ស្ពឺ។ ក្រោយពីនាងខ្ញុំរស់នៅជាមួយចុងចម្លើយអស់រយៈពេល ១២ឆ្នាំ មកនេះ នាងខ្ញុំ និងចុងចម្លើយតែងតែមិនចុះសម្រុងនឹងគ្នា ដោយសារមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ ដោយចុងចម្លើយមានស្រីនៅខាងក្រៅ ហើយនាងខ្ញុំបានហាមចុងចម្លើយជាច្រើនដង តែចុងចម្លើយនៅតែមិនព្រមកែខ្លួន ជាពិសេសចុងចម្លើយធ្លាប់ប្រើអំពើហិង្សាមកលើរូបនាងខ្ញុំថែមទៀត ហើយនាងខ្ញុំចេះតែទ្រាំរហូតមក មានពេលខ្លះចុងចម្លើយបានសុំនាងខ្ញុំលែងលះថែមទៀតផង តែនាងខ្ញុំមិនព្រមព្រោះនាងខ្ញុំមានការអាណិតដល់កូនខ្លាចកូនកំព្រា ដោយនៅពេលថ្មីៗនេះ ចុងចម្លើយតាមរករឿងនាងខ្ញុំមិនឈប់សោះ ហើយថែមទាំងចោទនាងខ្ញុំថា នាងខ្ញុំមានប្រុសទាំងដែលនាងខ្ញុំខំរកលុយផង ធ្វើការផង ដើម្បីរកលុយមកចិញ្ចឹមកូន បែរជាចុងចម្លើយមិនផ្តល់តម្លៃ ហើយមើលងាយដល់រូបនាងខ្ញុំថែមទៀត ដែលធ្វើឱ្យនាងខ្ញុំអស់នូវមនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធតទៅទៀតហើយ ទើបនាងខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងនេះតែម្តង។ នាងខ្ញុំ និងចុងចម្លើយបានព្រមព្រៀងគ្នា ដោយស្នើសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១.សុំផ្តាច់សមគ្គសង្វាស (លែងលះ) ពីចុងចម្លើយឈ្មោះ [redacted] ដារ៉ា [redacted] សារ៉ាត់)។

២.សុំគ្រប់គ្រងកូនឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ និងឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ មកចិញ្ចឹមបីបាច់ថែរក្សា។

៣.សុំទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនក្នុងមួយខែចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក។

៤.ទ្រព្យសម្បត្តិរួមមាន៖

ក.រថយន្តម៉ាក Prius ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ស្លាកលេខ ភ្នំពេញ ២BI-៧៩៥៧ នាងខ្ញុំសុំប្រគល់ឱ្យទៅចុងចម្លើយជាអ្នកគ្របគ្រង។

ខ.ផ្ទះថ្មទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ចុងចម្លើយ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ នាងខ្ញុំសុំប្រគល់ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង។

គ.ដីឡូត៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងដីឡូត៍លេខ Q៤៩ បណ្តោយ ២០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ ទំហំ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃគ្គី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល នាងខ្ញុំសុំគ្រប់គ្រង។

៥.បំណុលរួមមាន៖

ក.ជំពាក់ធនាគារ [redacted] ចំនួន ៤២,០៨៣.២៧ (បួនម៉ឺនពីរពាន់ប៉ែតសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក យកមកធ្វើផ្ទះនៅលើដីចុងចម្លើយខាងលើ សុំឱ្យចុងចម្លើយជាអ្នកសងបំណុលទៅធនាគារតែម្នាក់ឯង។

ខ.គុងទីនចំនួន ១០ ក្បាល លេងនៅស្នងការខេត្តកំពង់ស្ពឺ នាងខ្ញុំជាអ្នកទទួលបង់តែម្នាក់ឯង រហូតដល់បង់គុងទីនអស់។

៦.ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់នាងខ្ញុំ។



Scanned with CamScanner

-ចុងចម្លើយឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់ ធ្វើសេចក្តីថ្លែងការណ៍តបពីលទ្ធផលត្រៀមថា: ខ្ញុំបាទសុំឯកភាពលែងលះជាមួយដើមចោទ, ខ្ញុំបាទសុំឯកភាពប្រគល់កូនឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ និងឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រងកូន, ខ្ញុំបាទសុំឯកភាពបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក, ទ្រព្យសម្បត្តិរួមមាន: រថយន្តម៉ាក Prius ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ស្លាកលេខ ភ្នំពេញ ២BI-៧៩៥៧ ខ្ញុំបាទឯកភាពទទួលយករថយន្តមកគ្រប់គ្រង, ផ្ទះថ្មទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ខ្ញុំបាទ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ ខ្ញុំបាទឯកភាពទទួលយកមកគ្រប់គ្រងទុកជាកម្មសិទ្ធិ, ដីឡូត៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងដីឡូត៍លេខ Q៨៩ បណ្តោយ ២០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ ទំហំ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃភក្តី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ខ្ញុំបាទសុំប្រគល់ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រង និងបំណុលរួមមាន: ជំពាក់ធនាគារ [redacted] ចំនួន ៤២,០៨៣.២៧ (បួនម៉ឺនពីរពាន់សូន្យរយប៉ែតសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក ខ្ញុំបាទសុំឯកភាពជាអ្នកសងបំណុលតែម្នាក់ឯង, តុងទីនចំនួន ១០ ក្បាល លេងនៅស្នងការខេត្តកំពង់ស្ពឺ ខ្ញុំបាទសុំឯកភាពឱ្យដើមចោទជាអ្នកសងបំណុលតុងទីនតែម្នាក់ឯង, ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តីសុំឯកភាពឱ្យដើមចោទជាអ្នកទទួលបន្ទុក។ ដោយខ្ញុំបាទសុំបញ្ជាក់បន្ថែមចំនួនពីរចំណុចអាហារកាតព្វកិច្ចចិញ្ចឹមកូនទាំងពីរនាក់ក្នុងមួយខែចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក ខ្ញុំបាទសុំបង់ជារៀងរាល់ចុងខែ, ទាក់នឹងដីពីរកន្លែង ដីឡូត៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងដីឡូត៍លេខ Q៨៩ បណ្តោយ ២០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ ទំហំ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃភក្តី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលប្រគល់ឱ្យដើមចោទគ្រប់គ្រង គឺខ្ញុំបាទឱ្យដើមចោទគ្រប់គ្រងជាបណ្តោះអាសន្ន តែប៉ុណ្ណោះ នៅពេលកូនមាននីតិភាព គឺប្រគល់ឱ្យទៅកូនទាំងពីរនាក់ជាម្ចាស់កម្មសិទ្ធិ វិញ។

-ដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ធ្វើសេចក្តីថ្លែងការណ៍បន្ថែមថា: នាងខ្ញុំសុំឯកភាពតាមការស្នើសុំរបស់ចុងចម្លើយ។

-លោក [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់ ធ្វើសេចក្តីថ្លែងការណ៍ថា: ខ្ញុំបាទសុំឯកភាពតាមការព្រមព្រៀងរបស់កូនក្តីទាំងស្រុង។

-លោក [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់ ធ្វើសេចក្តីថ្លែងការណ៍ថា: ខ្ញុំបាទសុំឯកភាពតាមការព្រមព្រៀងរបស់កូនក្តីទាំងស្រុង។

-លោកស្រី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់ ធ្វើសេចក្តីថ្លែងការណ៍ថា: នាងខ្ញុំសុំឯកភាពតាមការព្រមព្រៀងរបស់កូនក្តីទាំងស្រុង។

**ភស្តុតាងជាឯកសារដែលភាគីដាក់ជូនតុលាការពិនិត្យរួមមាន៖**

១-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ០១ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០០៩ រវាងឈ្មោះ [redacted] អាយុវឌ្ឍ និងឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់។

២-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍លេខ: ០០២/០៩ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៩។

៣-សៀវភៅគ្រួសារលេខ: ៨១២០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦។

៤-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០។

៥-លិខិតទិញលក់រថយន្ត ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។

៦-បង្កាន់ដៃបង់ពន្ធយានយន្ត ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០។

៧-កិច្ចសន្យាលក់ទិញដីឡូត៍ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ រវាងក្រុមហ៊ុន [redacted] និងឈ្មោះ [redacted] អាយុវឌ្ឍ។

៨-សេចក្តីចម្លងសំបុត្រកំណើត ដែលមានសំបុត្របញ្ជាក់កំណើតលេខ: ២២៨ ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះ [redacted] អាយុវឌ្ឍ។

៩-សំបុត្របញ្ជាក់កំណើតលេខ: ៤៨៥៩ ឆ្នាំ២០០៥ រស់ឈ្មោះ [redacted] សារ៉ាត់។

១០-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ដែលមានសំបុត្រកំណើតលេខ: ០៦៣ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] សុវណ្ណបញ្ញា។

១១-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ដែលមានសំបុត្រកំណើតលេខ: ៣៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] គុណកល្យា។

១២-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ០៣០៩១០៨១៨ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] អាយុវឌ្ឍ។

១៣-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ០៣០៦០៧២៧១ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] សារ៉ាត់។

១៤-វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ។

១៥-លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន។

១៦-បណ្ណសម្គាល់យានយន្តស្លាកលេខ ២BI-៧៩៥៧ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ស៊ាងឡេង។

១៧-លិខិតទិញលក់រថយន្ត ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] ស៊ាងឡេង និងឈ្មោះ [redacted] អាយុវឌ្ឍ។

១៨-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ០៦១១០១០៧១(០១) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ស៊ាងឡេង។

១៩-លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ: ០៨២/១៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ប៊ុនថេត ឱ្យទៅឈ្មោះ [redacted] សារ៉ាត់ និងឈ្មោះ [redacted] អាយុវឌ្ឍ។

២០-គុងទីនក្បាល ២០០,០០០ រៀល ខែធ្នូ ឆ្នាំ២០១៨។

២១-តារាងទូទាត់ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រុមហ៊ុនពិភពដីមាស។

២២-លតាបត្ររថយន្តទេសចរណ៍ MC ១០១៩៨០០៨។

២៣-គណនីប្រភព ០០២៤៣៦៧១៣ ប្រាក់ដើមនៅសល់ចំនួន ៤២,០៨៣.២៧ (បួនម៉ឺនពីរពាន់ស្ទួនរយប៉ែតសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក។

**ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**-ចំណុចវិវាទ:** គ្មាន។

**-ចំណុចគ្មានវិវាទ:**

១-ឯកភាពលែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ដារ៉ា ([redacted] សារ៉ាត់)។

២-ឯកភាពប្រគល់កូនឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ និងឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រង។

៣-ឯកភាពបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនក្នុងមួយខែចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក។

៤-ទ្រព្យសម្បត្តិរួមមាន៖

ក-ឯកភាពប្រគល់រថយន្តម៉ាក Prius ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ស្លាកលេខ ភ្នំពេញ ២BI-៧៩៥៧ ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង។

ខ-ឯកភាពប្រគល់ផ្ទះថ្មទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ចុងចម្លើយ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង។

គ-ឯកភាពប្រគល់ដីឡូត៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងដីឡូត៍លេខ Q៨៩ បណ្តោយ ២០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ ទំហំ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃកក្តី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រងបណ្តោះអាសន្ន នៅពេលកូនមាននីតិភាពប្រគល់ឱ្យទៅកូនទាំងពីរនាក់។

៥-បំណុលរួមមាន៖

ក-ជំពាក់ធនាគារ [redacted] ចំនួន ៤២,០៨៣.២៧ (បួនម៉ឺនពីរពាន់ស្ទួនរយប៉ែតសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក យកមកធ្វើផ្ទះនៅលើដីចុងចម្លើយខាងលើ ឯកភាពឱ្យចុងចម្លើយជាអ្នកសងបំណុលទៅធនាគារតែម្នាក់ឯង។

ខ-តុងទីនចំនួន ១០ ក្បាល លេងនៅស្នងការខេត្តកំពង់ស្ពឺ ឯកភាពឱ្យដើមចោទជាអ្នកទទួលបង់តែម្នាក់ឯងរហូតដល់សងតុងទីនអស់។

៦-ឯកភាពឱ្យដើមចោទជាអ្នកបង់ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី។

**សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

**១-ស្តីពីការទាមទារទី១៖** ភាគីដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ សុំលែងលះពីភាគីចុងចម្លើយឈ្មោះ [redacted] ដារ៉ា ([redacted] សារ៉ាត់) ភេទប្រុស អាយុ ៣៨ឆ្នាំ។

-តាមពាក្យបណ្តឹងលែងលះ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ដែលអាចឱ្យតុលាការលើកយក

មកធ្វើការទាញហេតុផលតាមបទបញ្ញត្តិមាត្រា ៩ មាត្រា ២៣ និងចេញសាលក្រមតាមបទបញ្ញត្តិមាត្រា ១៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-ដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ និងចុងចម្លើយឈ្មោះ [redacted] ដារ៉ា ( [redacted] សារ៉ាត់) ភេទប្រុស អាយុ ៣៨ឆ្នាំ ពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាទៅតាមប្រពៃណីនៅក្នុងឆ្នាំ២០០៩ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ: ០១ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ: ០១/ ២០០៩ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ ត្រឹមត្រូវតាមច្បាប់។

-តាមការទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និងចុងចម្លើយបានឈានដល់ចំណុចបែកបាក់ ដែលគ្មានសង្ឃឹមថានឹងអាចស្រោចស្រង់បានឡើយ ហើយភាគីដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ សុំលែងលះពីភាគីចុងចម្លើយឈ្មោះ [redacted] ដារ៉ា ( [redacted] សារ៉ាត់) ភាគីចុងចម្លើយឯកភាពលែងលះតាមភាគីដើមចោទ។ ឃើញថាគូភាគីនៃអាពាហ៍ពិពាហ៍ បានព្រមព្រៀងអំពីការលែងលះគ្នា ដូច្នេះគប្បីតុលាការពិចារណា និងសម្រេចផ្អែកតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

-តាមមាត្រា ៩៥០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា: នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ (មួយរយម្ភៃ) ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។ ដូច្នេះគប្បីតុលាការសម្រេចបង្គាប់ឱ្យដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ នៅភាពជាមេម៉ាយចំនួន ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

**២-ស្តីពីការទាមទារទី២៖** ដើមចោទសុំសិទ្ធិអំណាចមេបាលើកូន ០២ (ពីរ) នាក់ កូនទី១ឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ និងទី២ឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩។

-តាមការអះអាងរបស់គូភាគីបានបញ្ជាក់ថា ក្នុងការរស់នៅជាមួយគ្នា ភាគីដើមចោទ និងភាគីចុងចម្លើយមានកូន ០២ (ពីរ) នាក់ កូនទី១ឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០០៩ និងទី២ឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩។ តាមលទ្ធផលនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីចុងចម្លើយបានថ្លែងការណ៍ថា: ខ្លួនឯកភាពប្រគល់កូនទាំងពីរនាក់ឱ្យទៅដើមចោទជាអ្នកមើលថែ។ ស្របតាមបញ្ញត្តិមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

**៣-ស្តីពីការទាមទារទី៣៖** ដើមចោទស្នើសុំឱ្យភាគីចុងចម្លើយបង់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនក្នុងមួយខែចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក។

-តាមការទាញហេតុផលដោយផ្ទាល់មាត់ ភាគីចុងចម្លើយបានបញ្ជាក់ថា ខ្លួនសុំឯកភាពផ្តល់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំងពីរនាក់ក្នុងមួយខែចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក តាមការស្នើសុំរបស់ដើមចោទ។

-យោងតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានចែងថា ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបាលើកូន មានករណីយកិច្ចទទួលបន្ទុកសោហ៊ុយដែល



Scanned with CamScanner

ចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ឪពុកម្តាយដែលមានបំណងចង់លែងលះ ត្រូវពិភាក្សាគ្នាកំណត់អំពីសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយភាគីដើមចោទ និងភាគីចុងចម្លើយបានឯកភាពគ្នាអំពីសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដូច្នេះគប្បីតុលាការតាមការព្រមព្រៀងរបស់គូភាគី។

-គប្បីឱ្យភាគីដែលមិនមានអំណាចមេបាលើកូន មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាកូន តាមបទបញ្ញត្តិមាត្រា ១០៨០ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

-គប្បីទុកសិទ្ធិឱ្យភាគីដែលមិនទទួលបានអំណាចមេបាលើកូន អាចប្រាស្រ័យទាក់ទងជាមួយកូនបានតាមកាលៈទេសៈសមរម្យ។

**៤-ស្តីពីការទាមទារទី៤៖** តាមពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ដើមចោទស្នើសុំបែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

៤.១-រថយន្តម៉ាក Prius ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ស្លាកលេខ ភ្នំពេញ **២BI-៧៩៥៧** ដើមចោទសុំគ្រប់គ្រង។

៤.២-ផ្ទះថ្មីទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ចុងចម្លើយ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ ដើមចោទសុំប្រគល់ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង។

៤.៣-ដីឡូតិ៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងដីឡូតិ៍លេខ Q៨៩ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃក្តី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល ដើមចោទសុំគ្រប់គ្រង។

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាទៅលើទ្រព្យសម្បត្តិរួមថាៈ

ក-ដើមចោទយល់ព្រមប្រគល់រថយន្តម៉ាក Prius ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ស្លាកលេខភ្នំពេញ **២BI-៧៩៥៧** និងផ្ទះថ្មីទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ចុងចម្លើយដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង។

ខ-ចុងចម្លើយយល់ព្រមប្រគល់ដីឡូតិ៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ តាមកិច្ចសន្យា ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០២០ រវាងក្រុមហ៊ុន [redacted] និងឈ្មោះ [redacted] **អារវឌ្ឍ** និងដីឡូតិ៍លេខ Q៨៩ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃក្តី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្តាល តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខៈ ០៨២/១៨ ១១ ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រង។

-យោងតាមបញ្ញត្តិមាត្រា ៩៨០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នាត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។ ដូច្នេះគប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។



Scanned with CamScanner

**៥-ស្ដីពីការទាមទារទី៥៖** បំណុលរួមជំពាក់ធនាគារ [redacted] ចំនួន ៤២,០៨៣.២៧ (បួនម៉ឺនពីរពាន់សាមសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក និងជំពាក់គុងទីនចំនួន ១០ ក្បាល លេងនៅស្នងការនគរបាលខេត្តកំពង់ស្ពឺ។

-តាមការទាញហេតុផលដោយផ្ទាល់មាត់ ភាគីដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នា ដោយភាគីចុងចម្លើយឈ្មោះ [redacted] ដារ៉ា ([redacted] សារ៉ាត់) យល់ព្រមទទួលខុសត្រូវបំណុលរួម ដែលជំពាក់ធនាគារ [redacted] ចំនួន ចំនួន ៤២,០៨៣.២៧ (បួនម៉ឺនពីរពាន់សាមសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក ហើយភាគីដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ យល់ព្រមទទួលខុសត្រូវបំណុលរួម ដែលជំពាក់គុងទីនចំនួន ១០ ក្បាល លេងនៅស្នងការនគរបាលខេត្តកំពង់ស្ពឺ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

**៦-ស្ដីពីការទាមទារទី៦៖** ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីដើមចោទ។

ភាគីដើមចោទសុំឱ្យបន្ទុកលើប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ខ្លួន ភាគីចុងចម្លើយបានយល់ព្រមតាមការស្នើសុំរបស់ភាគីដើមចោទ ហេតុដូច្នេះគប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

**៧-បានពិនិត្យឯកសារដែលមាន៖**

-សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ដែលមានសំបុត្រអាពាហ៍ពិពាហ៍ លេខ: ០១ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ រវាងឈ្មោះ [redacted] អាយុវឌ្ឍ និងឈ្មោះ [redacted] ដារ៉ា ហៅ [redacted] សារ៉ាត់។

-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍លេខ: ០០២/០៩ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៩។

-សៀវភៅគ្រួសារលេខ: ៨១២០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០។

-លិខិតទិញលក់រថយន្ត ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។

-បង្កាន់ដៃបង់ពន្ធយានយន្ត ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០។

-កិច្ចសន្យាលក់ទិញដីឡូត៍ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ រវាងក្រុមហ៊ុន [redacted] និងឈ្មោះ [redacted] អាយុវឌ្ឍ។

-សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ដែលមានសំបុត្របញ្ជាក់កំណើតលេខ: ២២៨ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះ [redacted] អាយុវឌ្ឍ។

-សំបុត្របញ្ជាក់កំណើតលេខ: ៨៨៥៩ ឆ្នាំ២០០៥ រស់ឈ្មោះ ញ៉ឹក សារ៉ាត់។

-សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ដែលមានសំបុត្រកំណើតលេខ: ០៦៣ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] សុវណ្ណបញ្ញា។

-សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ដែលមានសំបុត្រកំណើតលេខ: ៣៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] គុណកល្យា។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ០៣០៩១០៤១៨ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] អាយុវឌ្ឍ។



Scanned with CamScanner

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០៣០៦០៧២៧១ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] សារ៉ាត់។

-វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ។

-លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន។

-បណ្ណសម្គាល់យានយន្តស្លាកលេខ ២BI-៧៩៥៧ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ស៊ាងឡេង។

-លិខិតទិញលក់រថយន្ត ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] ស៊ាងឡេង និងឈ្មោះ [redacted] អាយុវឌ្ឍ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ០៦១១០១០៧១(០១) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ របស់ឈ្មោះ [redacted] ស៊ាងឡេង។

-លិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខៈ ០៨២/១៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ រវាងឈ្មោះ [redacted] សុខ និងឈ្មោះ [redacted] ប៊ុនថេត ឱ្យទៅឈ្មោះ [redacted] សារ៉ាត់ និងឈ្មោះ [redacted] អាយុវឌ្ឍ។

-តុងទីនក្បាល ២០០,០០០ រៀល ខែធ្នូ ឆ្នាំ២០១៨។

-តារាងទូទាត់ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រុមហ៊ុន [redacted]។

-លតាបត្ររថយន្តទេសចរណ៍ MC ១០១៨៨៩៩៥។

-គណនីប្រភព ០០២៨៣៦៧១៣ ប្រាក់ដើមនៅសល់ចំនួន ៨២,០៨៣.២៧ (ប៉ែតមុឺនពីរពាន់សូន្យរយប៉ែតសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក។

## <u>សេចក្តីសម្រេចបញ្ចប់</u>

I-ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ដោយឱ្យផ្តាច់សមគ្គសង្វាសជាប្តីប្រពន្ធ រវាងដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ និងចុងចម្លើយឈ្មោះ [redacted] ដារ៉ា (ញ៉ឹក សារ៉ាត់) ភេទប្រុស អាយុ ៣៨ឆ្នាំ។

II-ឱ្យឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ នៅភាពជាមេម៉ាយចំនួន ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

III-អំពីអំណាចមេបា៖

ក-ប្រគល់អំណាចមេបាលើកូនឈ្មោះ [redacted] សុវណ្ណបញ្ញា ភេទប្រុស កើតថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០០៩ និងឈ្មោះ [redacted] គុណកល្យា ភេទស្រី កើតថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ឱ្យទៅដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ភេទស្រី អាយុ ៣៥ឆ្នាំ ជាអ្នកមានអំណាចមេបា រហូតដល់កូនទទួលបាននីតិភាពតាមផ្លូវច្បាប់។

ខ-ឱ្យចុងចម្លើយផ្តល់សោហ៊ុយ ដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនក្នុងមួយខែចំនួន ៤០០,០០០ (សែសិបម៉ឺន) រៀល។

ទុកសិទ្ធិឱ្យភាគីដែលមិនទទួលបានអំណាចមេបាលើកូន អាចប្រាស្រ័យទាក់ទងជាមួយកូនបានតាមកាលៈទេសៈសមរម្យ។



Scanned with CamScanner

IV-ទ្រព្យសម្បត្តិរួម៖

ក-ប្រគល់រថយន្តម៉ាក Prius ពណ៌ទឹកប្រាក់ ឆ្នាំ២០០៧ ស្លាកលេខ ភ្នំពេញ ២BI-៧៩៥៧ និងផ្ទះថ្មីទំហំ (៦x២២) ម៉ែត្រ សាងសង់នៅលើដីដោយឡែករបស់ចុងចម្លើយ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ០៥០២០៤១០-០៣៨៧ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ដារ៉ា ([redacted] សារ៉ាត់) ជាអ្នកគ្រប់គ្រង។

ខ-ប្រគល់ដីឡូត៍លេខ X២០៤ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិអណ្តូងច្រុះ ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ តាមកិច្ចសន្យា ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ រវាង [redacted] និងឈ្មោះ [redacted] អារុវឌ្ឍ និងដីឡូត៍លេខ Q៨៩ ទំហំ (៥x២០) ម៉ែត្រ ស្មើ ១០០ ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃក្ដី ឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្ដាល តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ: ០៨២/១៥ ១១ ឱ្យទៅដើមចោទឈ្មោះ [redacted] អាយុវឌ្ឍ ជាអ្នកគ្រប់គ្រង។

V-ការទទួលខុសត្រូវលើបំណុលរួមតាមការព្រមព្រៀង៖

ក-ឱ្យចុងចម្លើយឈ្មោះ [redacted] ដារ៉ា ([redacted] សារ៉ាត់) ជាអ្នកសងបំណុលរួមជំពាក់ធនាគារ [redacted] ចំនួន ៤២,០៨៣.២៧ (បួនម៉ឺនពីរពាន់ស្វន្សរយប៉ែតសិបបីក្បៀសម្ភៃប្រាំពីរ) ដុល្លារអាមេរិក រហូតដល់ចុងចម្លើយសងបំណុលអស់។

ខ-ឱ្យដើមចោទឈ្មោះ [redacted] អារុវឌ្ឍ ជាអ្នកសងបំណុលជំពាក់តុងទីនចំនួន ១០ ក្បាល លេងនៅស្នងការនគរបាលខេត្តកំពង់ស្ពឺ រហូតដល់ដើមចោទសងតុងទីនអស់។

VI-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

VII-សាលក្រមនេះប្រកាសជាអសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង ៣០ នាទី ព្រឹក នៅសាលសវនាការ នៃសាលាដំបូងខេត្តកំពង់ស្ពឺ។

បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ចៅក្រម

ហត្ថលេខា និងត្រា[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅកំពង់ស្ពឺ, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner